# ជាឱកាសដែលបាត់បង់ ឬជាក្ដីសង្ឃឹមចុងក្រោយ? ការចោទប្រកាន់បទឧក្រិដ្ឋរំលោភផ្លូវភេទក្រោមរបបខ្មែរក្រហម

ថេរេសា ឌី ឡេនហ្គីស[1]

ក្នុងរយៈពេលពីរទសវត្សរ៍កន្លងទៅ កាតព្វកិច្ចជាអន្តរជាតិជាច្រើនត្រូវបានបង្កើតឡើងដើម្បីពង្រឹងការយកចិត្តទុកដាក់ចំពោះយន្តការដាក់លាក់មួយចំនួន ដែលស្ត្រីធ្លាប់ទទួលរងនៅក្នុងអំឡុងពេលនៃជម្លោះប្រដាប់អាវុធ និងអំពើសាហាវព្រៃផ្សៃ និងដាក់ឲ្យមានការទទួលខុសត្រូវចំពោះអំពើរំលោភបំពានទាំងឡាយទាក់ទងនឹងបញ្ហាយេនឌ័រ ។ ក្នុងចំណោមយន្តការទាំងនេះ សេចក្តីសម្រេចមួយចំនួនរបស់ក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិ ជារឿយៗត្រូវបានស្គាល់ថា ជាសេចក្តីសម្រេចចិត្តទាក់ទងនឹងរបៀបវារៈស្តីអំពីសន្តិសុខ និងសន្តិភាពសម្រាប់ស្ត្រី ដែលបានអំពាវនាវឲ្យមានការស៊ើបអង្កេតដោយហ្មត់ចត់ និងមានលក្ខណៈសមស្រប និងធ្វើយ៉ាងណាជំរុញឲ្យមានការកាត់ទោសចំពោះអំពើហិង្សាផ្លូវភេទដែលកើតឡើងនៅអំឡុងពេលដែលជម្លោះកើតឡើង ដោយសង្កត់ធ្ងន់លើការបញ្ហាដែលមានជាប់ពាក់ព័ន្ធនឹងការរើសអើងទាក់ទងនឹងយេនឌ័រ និងការជិះជាន់លើស្ត្រី ជាកត្តារួមចំណែក និងជាដើមហេតុនៃជម្លោះ[2] ។ កាលពីពេលថ្មីៗនេះ

---

[1] ថេរេសា ឌី ឡេនហ្គីស គឺជាអ្នកជំនាញជាន់ខ្ពស់អំពីសិទ្ធិស្ត្រីនៅក្នុងបរិបទជម្លោះ និងក្រោយជម្លោះ ដោយផ្តោតលើតំបន់អាស៊ីប៉ាស៊ីហ្វិក ។ លោកស្រីបានមកបម្រើការនៅទីក្រុងភ្នំពេញចាប់តាំងពីឆ្នាំ២០១២ ដោយបានចូលរួមតស៊ូមតិដើម្បីលើកកម្ពស់ការយល់ដឹងអំពីឧក្រិដ្ឋកម្មទាក់ទងនឹងអំពើហិង្សាផ្លូវភេទក្រោមរបបខ្មែរក្រហមនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

[2] សូមមើលឯកសារអង្គការសហប្រជាជាតិS/RES/1325(ឆ្នាំ២០០០); ឯកសារអង្គការសហប្រជាជាតិS/RES/1820(ឆ្នាំ២០០៨) ឯកសារអង្គការសហប្រជាជាតិ S/RES/1888 (ឆ្នាំ២០០៩); ឯកសារអង្គការសហប្រជាជាតិ S/RES/1889 (ឆ្នាំ២០០៩); ឯកសារអង្គការសហប្រជាជាតិ S/RES/1960 (ឆ្នាំ២០១០); ឯកសារអង្គការសហប្រជាជាតិ S/RES/2106 (ឆ្នាំ២០១៣); ឯកសារអង្គការសហប្រជាជាតិ S/RES/2122 (ឆ្នាំ២០១៣) ។ សូមមើលរបាយការណ៍របស់អគ្គលេខាធិការស្តីអំពីអំពើហិង្សាពាក់ព័ន្ធនឹងផ្លូវភេទនៅក្នុងជម្លោះ ទី១) ឯកសារអង្គការសហប្រជាជាតិ S/2014/181 (ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៤) (កំណត់និយមន័យ "អំពើហិង្សាទាក់ទងនឹងផ្លូវភេទនៅក្នុងជម្លោះ" ដូចជា "ការរំលោភ ការបង្ខំឲ្យធ្វើជាស្រីពេស្យាចារ ការមានគភ៌ដោយបង្ខំ ការចាក់ថ្នាំមិនឲ្យមានកូន និងទម្រង់ផ្សេងៗនៃអំពើហិង្សាផ្លូវភេទ ដែលមានភាពធ្ងន់ធ្ងរប្រហាក់ប្រហែលនឹងស្ត្រី បុរស និងកុមារដែលមានជាប់ទាក់ទងដោយផ្ទាល់ ឬប្រយោលទៅនឹងជម្លោះ ។ ការភ្ជាប់ទៅនឹងជម្លោះអាចត្រូវបានស្តែងឡើងនៅក្នុងសាច់រឿងរបស់ជនដៃដល់ សាច់រឿងរបស់ជនរងគ្រោះ ស្ថានភាពនៃនិទ្ទណ្ឌភាព ឬការធ្លាក់ចុះទន់ខ្សោយនៃរដ្ឋ ការដើរហួសពីព្រំដែនដែលត្រូវបានអនុញ្ញាត ឬការរំលោភរំពានលើកិច្ចព្រមព្រៀងឈប់បាញ់" ។

គណៈកម្មការតាមដានការអនុវត្តអនុសញ្ញាស្តីអំពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រី បានប្រកាសអំពីអនុសាសន៍ទូទៅចំនួន៣០ចំណុច ដោយសង្កត់ធ្ងន់លើការអនុវត្តសន្ធិសញ្ញាក្នុងស្ថានភាពនៃអំឡុងពេលមានជម្លោះ និងក្រោយជម្លោះ និងការបំពេញបន្ថែមនូវចន្លោះខ្វះខាតដែលមាននៅក្នុងច្បាប់មនុស្សធម៌អន្តរជាតិ និងច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិ ។[៣]

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ត្រូវបានបង្កើតឡើងស្ថិតនៅក្រោមច្បាប់ប្រទេសកម្ពុជា នៅក្នុងឆ្នាំ២០០៤ ដើម្បីនាំយកមេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលបានកើតឡើងក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ នៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ មកជំនុំជម្រះទោស ។

ទោះបីជាមានការគាំទ្រពីសំណាក់អង្គការសហប្រជាជាតិយ៉ាងណាក្តី ក៏តុលាការចម្រុះមួយនេះស្ថិតក្រោមប្រព័ន្ធតុលាការរបស់កម្ពុជា ដែលមានចៅក្រម ព្រះរាជអាជ្ញា និងមន្ត្រីតុលាការជាតិ និងអន្តរជាតិធ្វើការរួមគ្នា ។[៤] បច្ចុប្បន្នមានសំណុំរឿងចំនួន៤ នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (សំណុំរឿង ០០១ ដល់សំណុំរឿង០០៤) ។

សំណុំរឿង០០២បានចាប់ផ្តើមសវនាការនៅក្នុងខែវិច្ឆិកា ឆ្នាំ២០១១ ហើយត្រូវបានចាត់ទុកថាជាសំណុំរឿងដ៏សំខាន់នៅក្នុងច្បាប់អន្តរជាតិ ដោយសារទម្ងន់នៃបទឧក្រិដ្ឋ និងកម្រិតដឹកនាំរបស់ជនជាប់ចោទ ។ ឯកអគ្គរាជទូតគោចរសហរដ្ឋអាមេរិកទទួលបន្ទុកខាងឧក្រិដ្ឋកម្មសង្គ្រាម លោក ស្ទេហ្វិន រ៉ាប បានចាត់ទុកសំណុំរឿង០០២ថា "ជាសំណុំរឿងដែលសំខាន់ជាទីបំផុតនៅក្នុងពិភពលោក" នាពេលបច្ចុប្បន្ន ។[៥] ទោះបីជាយ៉ាងនេះក៏ដោយ កេរដំណែលរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលទទួលបានពីសំណុំរឿង០០២ នឹងបង្ហាញអំពីភាពនៅមានកម្រិតក្នុងការឈានទៅសិក្សាពីមេរៀនរបស់តុលាការមុនៗ

---

[៣] អនុសាសន៍រួមលេខ៣០ ស្តីអំពីស្ត្រីនៅក្នុងការទប់ស្កាត់ជម្លោះ ហេតុការណ៍ក្នុងអំឡុងពេល និងក្រោយពេលជម្លោះកើតឡើង ។ ឯកសារអង្គការសហប្រជាជាតិ CEDAW/C/GC/30 (ឆ្នាំ២០១៣) ។

[៤] សម្រាប់ព័ត៌មានបន្ថែមស្តីអំពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សូមមើល The Khmer Rouge Tribunal (John D. Ciorciari., មជ្ឈមណ្ឌលឯកសារកម្ពុជា ឆ្នាំ២០០៦) ។

[៥] សន្និសីទកាសែត, ការិយាល័យស្តីអំពីបញ្ហាឧក្រិដ្ឋកម្មសង្គ្រាម, ក្រសួងការបរទេសសហរដ្ឋអាមេរិកប្រកាសការចូលរួមវិភាគទានដល់សាលាក្តីខ្មែរក្រហម (ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១១) www.state.gov/j/gcj/us_releases/other/2011/175540.htm ។ ជនជាប់ចោទ នួន ជា និង ខៀវ សំផន គឺជាសមាជិកជាន់ខ្ពស់បំផុតដែលកំពុងរស់រានមានជីវិត និងមានសម្បទាគ្រប់គ្រាន់ដើម្បីចូលរួមសវនាការ ។ បទចោទទាំងនេះរួមមាន ឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងសង្គ្រាម និងអំពើប្រល័យពូជសាសន៍ ។

ក្នុងការដោះស្រាយឧក្រិដ្ឋកម្មទាក់ទងនឹងការរំលោភបំពានផ្លូវភេទ ។ មូលហេតុចម្បង គឺដោយសារភាពស្មុគស្មាញ និងវិធីសាស្ត្រដែលមានលក្ខណៈចង្អៀតរបស់តុលាការក្នុងការជ្រើសរើសយកត្រឹមតែផ្នែកមួយនៃបញ្ហាឧក្រិដ្ឋកម្មទាំងមូលដែលបានប្រព្រឹត្តឡើងក្នុងពេលនៃរបបខ្មែរក្រហម ។

ការិយាល័យសហព្រះរាជអាជ្ញាពុំបានស្នើសុំឲ្យមានការស៊ើបអង្កេតបឋមលើអង្គហេតុទាក់ទងនឹងការរៀបការដោយបង្ខំនៅក្នុងសំណុំរឿង០០២ទេ រហូតទាល់តែមានការតស៊ូមតិយ៉ាងខ្លាំងពីសំណាក់ដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវី ទើបការិយាល័យសហព្រះរាជអាជ្ញាស្នើសុំឲ្យមានការស៊ើបសួរបន្ថែម ។[៦] បន្ទាប់មកចៅក្រមស៊ើបអង្កេត រកឃើញភស្តុតាងដែលបង្ហាញថា ការរៀបការដោយបង្ខំបានកើតឡើងស្ទើរគ្រប់តំបន់«ក្នុងអំឡុងរបបខ្មែរក្រហម» ។[៧] បច្ចុប្បន្ន បទចោទទាក់ទងនឹងការរៀបការដោយបង្ខំ គឺមានដើមបណ្តឹងរដ្ឋប្បវេណីចំនួនច្រើនលំដាប់ទីពីរ បន្ទាប់ពីអង្គហេតុទាក់ទងនឹងការជម្លៀសដោយបង្ខំ ដែលមានចំនួនដើមបណ្តឹងច្រើនជាងគេ ដោយសារតែការអនុវត្តគោលនយោបាយរបស់ខ្មែរក្រហម ។ ឧក្រិដ្ឋកម្មដែលត្រូវបានជំនុំជម្រះក្តីដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានលក្ខណៈពិសេស ដោយហេតុថា បុរសក៏ត្រូវបានបង្ខំឲ្យរៀបការ និងទទួលរងផលប៉ះពាល់ទាំងខាងផ្លូវចិត្ត និងសង្គម ដោយសារឧក្រិដ្ឋកម្មនោះដូចគ្នា ។ យ៉ាងហោចណាស់មានករណីមួយដែលត្រូវបានរាយការណ៍ថា បុរសជាប្តីត្រូវបានបង្ខំឲ្យរំលោភប្រពន្ធរបស់ខ្លួន ដោយក្រុមខ្មែរក្រហមបានចាប់ផ្តួលស្ត្រីជាប្រពន្ធទៅក្រោម ហើយករណីបែបនេះបានកើត

---

[៦] សម្រាប់ព័ត៌មានស្តីអំពីដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីតំណាង ក្នុងការតស៊ូមតិដើម្បីឲ្យមានការចោទប្រកាន់លើអង្គហេតុទាក់ទងនឹងការរៀបការដោយបង្ខំ ដែលនាំឲ្យមានការស្នើសុំឲ្យស៊ើបសួរបន្ថែមរបស់ការិយាល័យសហព្រះរាជអាជ្ញានៅក្នុងឆ្នាំ២០០៩ សូមមើល Silke Studzinsky, *One Eye Blind? Is the ECCC a Model of How Sexual Violence Crimes Should Be Investigated and Treated?*, Gerda Werner Institute: Feminism and Democracy (ឆ្នាំ២០១២), [www.gwi-boell.de/web/violenceconflict-international-criminal-court-model-of-how-sexual-crimes-should-be-investigated-andtreated-4573.html](www.gwi-boell.de/web/violenceconflict-international-criminal-court-model-of-how-sexual-crimes-should-be-investigated-andtreated-4573.html). ។ សូមមើល, ដីកាស្តីពីសំណើសុំឲ្យចាត់វិធានការស៊ើបអង្កេតសួរបន្ថែមទាក់ទងនឹងការរៀបការដោយបង្ខំ និងការបង្ខំឲ្យរួមដំណេក, សំណុំរឿង០០២/ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧-អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា-ការិយាល័យសហចៅក្រមស៊ើបអង្កេត (ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៩) ។

[៧] ដីកាដំណោះស្រាយ, សំណុំរឿង០០២/ថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០០៧-អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា-ការិយាល័យសហចៅក្រមស៊ើបអង្កេត, កថាខណ្ឌ៨៤៣ ដល់៨៤៤ (ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០) (សេចក្តីយោងត្រូវបានលុបចោល) ។ សូមមើល បេនី យេ «អាពាហ៍ពិពាហ៍ដោយបង្ខំគឺជាកញ្ចក់ឆ្លុះបញ្ចាំងអំពីការដោះស្រាយជម្លោះនៅកម្ពុជា, 23 Peace Rev. ទំព័រ៤៦៩ ដល់៤៧៥ (ឆ្នាំ២០១១) ។

ឡើងជាទូទៅចំពោះគូស្វាមីភរិយាដែលចចេសរឹងរូសពុំព្រមរួមដំណេក ដែលកម្មវត្ថុនៃការនាំយកទៅអប់រំអំពីការរួមដំណេក ឬប្រឈមមុខនឹងទណ្ឌកម្ម ឬប្រឈមនឹងការនាំយកទៅសម្លាប់ ។[៨]

អ្វីដែលសំខាន់ ដីកាដំណោះស្រាយក្នុងសំណុំរឿង០០២ ចាត់ទុកអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈដែលស្ថិតនៅក្នុងបរិបទនៃការរៀបការដោយបង្ខំ ថាជាធាតុផ្សំចម្បងមួយដែលស្ថិតនៅក្រោមការត្រួតត្រាក្នុងអំឡុងពេលនៃរបបខ្មែរក្រហម ។[៩] ប៉ុន្តែ ខណៈដែលដីកាដំណោះស្រាយចង្អុលបង្ហាញអំពីករណីមួយចំនួនពាក់ព័ន្ធនឹងអំពើហិង្សាផ្លូវភេទ រួមមានការរំលោភសេពសន្ថវៈនៅក្នុងមន្ទីរសន្តិសុខ ស្រាប់តែដីកានេះបែរជាកំណត់ថា ជនជាប់ចោទមិនជាប់ពាក់ពន្ធ័នឹងបទឧក្រិដ្ឋទាំងនេះទេ ដោយសារខ្មែរក្រហមមានគោលបំណងទប់ស្កាត់មិនឲ្យមានការរំលោភបំពានទាំងនេះ តាមរយៈគោលនយោបាយផ្លូវការរបស់ខ្លួន ។[១០]

សេចក្តីសន្និដ្ឋាននៅក្នុងដីកាដំណោះស្រាយត្រូវបានតវ៉ាយ៉ាងស្វិតស្វាញ រួមមានការសិក្សាស្រាវជ្រាវ និងការចងក្រងជាឯកសារស្តីអំពីអំពើហិង្សាផ្លូវភេទ និងអំពើហិង្សាផ្អែកយេនឌ័រក្នុងរបបខ្មែរក្រហម ដែលប្រព្រឹត្តដោយកម្មាភិបាល និងមន្ត្រីខ្មែរក្រហមទាំងក្នុង និងក្រៅបរិបទនៃការរៀបការដោយបង្ខំ ។[១១]

---

[៨] ថេរេសា ឌី ឡេនហ៊ិស, បទសម្ភាសន៍ផ្ទាល់ខ្លួន, សេចក្តីអត្ថាធិប្បាយលេខ១៩, គម្រោងប្រវត្តិសាស្ត្រផ្ទាល់មាត់របស់ស្ត្រីកម្ពុជា (ថ្ងៃទី១៩-២០ ខែកុម្ភៈ ឆ្នាំ២០១៤) ។

[៩] សូមមើលដីកាដំណោះស្រាយ, កថាខណ្ឌ១៨៣០ និងកថាខណ្ឌ១៨៤១ ។

[១០] ដូចខាងលើ ។ កថាខណ្ឌ១៨២៦ និង កថាខណ្ឌ១៨២៩ (ដោយរកឃើញថា "វាត្រូវបានបង្កើតឡើងនៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ [របបខ្មែរក្រហម] ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិទាក់ទងនឹងការរំលោភសេពសន្ថវៈត្រូវបានប្រព្រឹត្តឡើងនៅក្នុងកាលៈទេសៈផ្សេងៗគ្នា ជាពិសេសនៅតាមបណ្តាមន្ទីរសន្តិសុខ" ប៉ុន្តែបែរជាធ្វើការសន្និដ្ឋានថា "គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា [ខ្មែរក្រហម] ទាក់ទិននឹងការរំលោភសេពសន្ថវៈ គឺធ្វើឡើងដើម្បីទប់ស្កាត់ការកុំឲ្យកើតមាន និងដើម្បីដាក់ទណ្ឌកម្មចំពោះជនដែលល់ទៅវិញ" ) ។

[១១] សូមមើលអត្ថបទរបស់ កល្យាណី ម៉ម "ភ័ស្តុតាងនៃការរំលោភផ្លូវភេទ ក្នុងអំឡុងនៃការកាន់អំណាចរបស់កម្ពុជាប្រជាធិបតេយ្យ" ទស្សនាវដ្តីស្វែងរកការពិត លេខ១៥ (មជ្ឈមណ្ឌលឯសារកម្ពុជា ខែមីនា ឆ្នាំ២០០១) http://www.d.dccam.org/Projects/Magazines/Previous%20Englis/Issue15.pdf; ណាកាហ្គាវ៉ា កាស៊ូមី "អំពើហិង្សាដោយផ្អែកលើយេនឌ័រក្នុងអំឡុងរបបខ្មែរក្រហម : រឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩) ។ (ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា ឆ្នាំ២០០៨); សូ ហ្វារីណា "ស្ត្រីកម្ពុជា : ការចងចាំរបស់ស្ត្រីអ៊ិស្លាមបន្ទាប់ពីរបបខ្មែរក្រហម ឆ្នាំ២០១១) ។ ឌួង សាវ៉ន "អាថ៌កំបាំងនៃអំពើហិង្សាផ្លូវភេទក្រោមរបបខ្មែរក្រហម (ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា ខែមិថុនា ឆ្នាំ២០១១); កាទ្រីណា ណាថាឡេ "ខ្ញុំមានអារម្មណ៍ដូចជា ព្រលឹងរបស់ខ្ញុំកំពុងហោះចេញពីខ្លួន

វេទិកាស្តាប់សំឡេងស្ត្រីកម្ពុជាលើកដំបូងស្តីអំពីការរំលោភបំពានផ្លូវភេទនៅក្នុងរបបខ្មែរក្រហម ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០១១ ដោយអង្គការសិទ្ធិមនុស្សក្នុងស្រុកមួយដែលមានឈ្មោះថា ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា (ស៊ី.ឌី.ភី) ដែលរៀបចំជាព្រឹត្តិការណ៍ឲ្យជនរងគ្រោះ និងសាក្សី រៀបរាប់ពីការពិត ដើម្បីផ្តល់សក្ខីកម្មជាសាធារណៈអំពីឧក្រិដ្ឋកម្មដែលទទួលរង រួមមានការថ្លែងអំពីការរំលោភមុនពេលសម្លាប់ ការរំលោភផ្លូវភេទទុកជាវិធីសាស្ត្រសម្រាប់ធ្វើទារុណកម្ម ការរំលោភជាក្រុម និងការរំលោភផ្ទួនៗ និងការរំលោភដោយប្រើឧបករណ៍ដើម្បីបំផ្លាញអវៈយវៈភេទ ។ នៅក្នុងឧទាហរណ៍នីមួយៗ ជនដៃដល់ត្រូវបានស្គាល់ថា ជាភ្នាក់ងារនៃរបបនេះ ប៉ុន្តែមិនមានការដាក់ទណ្ឌកម្មណាមួយលើជនទាំងនេះត្រូវបានបង្ហាញឡើយ[១៧] ។

ម៉ាហ្កត វ៉លស្ត្រម អតីតអ្នកតំណាងពិសេសរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកផ្នែកអំពើហិង្សាផ្លូវភេទនៅក្នុងអំឡុងពេលមានជម្លោះ បានថ្លែងសារតាមរយៈវីដេអូនៅក្នុងវេទិកាស្តាប់សំឡេងស្ត្រី ហើយប្រធានទទួលបន្ទុកផ្នែកបុគ្គលិករបស់គាត់ឈ្មោះ ណាន់ស៊ី អូគូ ប្រាយណ៍ បានថ្លែងសុន្ទរកថាសំខាន់ៗ និងអង្កេតមើលទិដ្ឋភាពរួមនៃវេទិកានេះ ។ បន្ទាប់ពីមានវេទិកានេះ លោក វ៉លស្ត្រម បានផ្ញើលិខិតមួយជូនអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា រដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ ព្រមទាំងបានបោះពុម្ពផ្សាយលិខិតនោះជាសាធារណៈនៅក្នុងកាសែតភ្នំពេញប៉ុស្តិ៍ជាភាសាអង់គ្លេស ដោយជំរុញឲ្យតុលាការប្រើប្រាស់ធនធានឲ្យអស់ពីសមត្ថភាព ដើម្បីដោះស្រាយឧក្រិដ្ឋកម្មរំលោភបំពានផ្លូវភេទ រួមមាន បើកការស៊ើបអង្កេត និងការពង្រីកវិសាលភាពចំពោះការចោទប្រកាន់ ក៏ដូចជាការទទួលស្គាល់

---

របស់ខ្ញុំ ៖ ការសិក្សាអំពីអំពើហិង្សាដោយផ្អែកលើយេនឌ័រក្នុងអំឡុងរបបខ្មែរក្រហម នៅក្នុងខេត្តបាត់ដំបង និងខេត្តស្វាយរៀង (ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា) ។ អាចរកអានបានតាមរយៈគេហទំព័រ http://gbvkr.org/wp-content/uploads/2013/01/Natale_K_Research_GBV_KR_ENG-web.pdf; ថេរេសា ឌី ឡេនហ្គីស និង ស៊ីលកេ ស្ទុទហ្សិនស្គី, សំណេរសង្ខេបស្តីអំពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សវនាការអំពីស្ត្រីកម្ពុជាដើម្បីដោះស្រាយអំពើហិង្សាក្រោមរបបខ្មែរក្រហម (ខែឧសភា ឆ្នាំ២០១២) (សំណេរដែលមិនទាន់ត្រូវបានបោះពុម្ពផ្សាយមាននៅជាមួយអ្នកនិពន្ធ, ថេរេសា ឌី ឡេងឹស គម្រោងប្រវត្តិសាស្ត្រផ្ទាល់មាត់របស់ស្ត្រីកម្ពុជា (ឆ្នាំ២០១៣) ។ www.cambodianwomensoralhistory.com.

[១៧] សូមមើលអង្គការក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា, របាយការណ៍ស្តីអំពីដំណើរការនៃវេទិកាស្តាប់សំឡេងស្ត្រី ឆ្នាំ២០១១ ទាក់ទងនឹងអំពើហិង្សាផ្លូវភេទក្រោមរបបខ្មែរក្រហម (ខែឧសភា ឆ្នាំ២០១២) http://gbvkr.org/wp-content/uploads/2013/01/Report-on-2011-Womens-Hearing_Phnom-Penh.pdf. វេទិកាស្តាប់សំឡេងស្ត្រីត្រូវបានរៀបចំឡើងនៅក្នុងឆ្នាំ២០១២ និង២០១៣ ផងដែរ ។

និងផ្តល់សំណងឲ្យបានគ្រប់គ្រាន់ដល់ជនរងគ្រោះ ។[១៣] ចាប់តាំងពីពេលនោះមក ប្រទេសកម្ពុជាត្រូវបានលើកឡើងនៅគ្រប់របាយការណ៍ប្រចាំឆ្នាំរបស់អគ្គលេខាអង្គការសហប្រជាជាតិស្តីអំពីជម្លោះទាក់ទិននឹងការរំលោភផ្លូវភេទ ។[១៤] គណៈកម្មាការលុបបំបាត់រាល់ការរើសអើងប្រឆាំងនឹងស្ត្រីរបស់អង្គការសហប្រជាជាតិបានបង្ហាញពីកង្វល់របស់ខ្លួនថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមិនបានដោះស្រាយអំពើហិង្សាផ្លូវភេទ និងបញ្ហាយេនឌ័រ នៅក្នុងរបបខ្មែរក្រហមឲ្យបានគ្រប់គ្រាន់នៅឡើងទេ ។ នៅក្នុងការអង្កេតចុងក្រោយស្តីពីរបាយការណ៍អំពីប្រទេសកម្ពុជាលើកទី៤ និងទី៥ ដែលរួមបញ្ចូលគ្នានៅក្នុងឆ្នាំ២០១៣ គណៈកម្មការលុបបំបាត់រាល់ការរើសអើងប្រឆាំងនឹងស្ត្រី ស្នើឲ្យមានសំណងសម្រាប់ជនរងគ្រោះ“ប្រកបដោយប្រសិទ្ធភាព” រួមមានការប៉ះប៉ូវ និងការបញ្ចូលបញ្ហាទាំងនេះទៅក្នុងគោលនយោបាយ និងយុទ្ធសាស្ត្រជាតិក្នុងគោលបំណងដោះស្រាយអំពើហិង្សាប្រឆាំងនឹងស្ត្រីនាពេលបច្ចុប្បន្ន[១៥] ។

ក្នុងការឆ្លើយតបចំពោះការអំពាវនាវឲ្យចាត់វិធានការរបស់ វ៉លស្ត្រូម និងសកម្មជនដទៃទៀត អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានលើកឡើងថា ខ្លួនគ្មានសមត្ថកិច្ចដើម្បី“បន្ថែមអង្គហេតុ ឬបទចោទថ្មីៗទៅក្នុងដីកាដំណោះស្រាយទេ ។[១៦] នៅថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងសារជាថ្មីថា ការជំនុំជម្រះសេចក្តីទៅលើឧក្រិដ្ឋកម្មទាក់ទងនឹងអំពើ

---

[១៣] ម៉ាហ្គត វ៉លស្ត្រូម (Margot Wallstrom) “ជនរងគ្រោះក្នុងរបបខ្មែរក្រហមដែលត្រូវបានបំភ្លេចចោល, កាសែតភ្នំពេញប៉ុស្តិ៍ ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១២ អាចរកបាននៅលើគេហទំព័រ www.phnompenhpost.com/national/forgotten-khmer-rouge-victims.

[១៤] ដូចគ្នានឹងកំណត់សម្គាល់ជើងទំព័រលេខ២ខាងលើ, របាយការណ៍របស់អគ្គលេខាធិការអង្គការសហប្រជាជាតិ កថាខណ្ឌ៦៨ (“ចាប់តាំងពីការចេញរបាយការណ៍មុនៗរបស់ខ្ញុំស្តីពីអំពើហិង្សាផ្លូវភេទនៅក្នុងជម្លោះ នៅពុំទាន់មានការរៀបចំជាប្រព័ន្ធណាមួយត្រូវបានធ្វើឡើងដើម្បីឆ្លើយតបទៅនឹងការផ្តល់អនុសាសន៍របស់ខ្ញុំនៅឡើយទេ ដែលអនុសាសន៍នេះគឺដើម្បីធ្វើឲ្យមានប្រសិទ្ធភាពក្នុងការកាត់សេចក្តីជនដៃដល់) ។ សូមមើលផងដែរនូវរបាយការរបស់អគ្គលេខាធិការស្តីអំពីអំពើហិង្សាផ្លូវភេទនៅក្នុងជម្លោះ កថាខណ្ឌ១១៤ ឯកសារអង្គការសហប្រជាជាតិ A/67/792–S/2013/149 (២០១៣) ។

[១៥] ការអង្កេតចុងក្រោយទៅលើរបាយការណ៍វគ្គ៤ និង៥ ស្តីអំពីប្រទេសកម្ពុជា គណៈកម្មាការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រី កិច្ចប្រជុំលើកទី៥៦ ឯកសារអង្គការសហប្រជាជាតិ CEDAW/C/KHM/CO/4-5 ទំព័រ៣–៤(ឆ្នាំ២០១៣) ។

[១៦] សូមមើល អនុសារណៈមកពីចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ សម្រាប់ព័ត៌មានបន្ថែមទាក់ទងនឹងការជំទាស់ដំបូងទាំងឡាយ កថាខណ្ឌ៣ (ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៤) ។

ហិង្សាផ្លូវភេទក្នុងរបបខ្មែរក្រហមនៅក្នុងសំណុំរឿង០០២ នឹងកំហិតត្រឹមតែអង្គហេតុទាក់ទងនឹងការរៀបការដោយបង្ខំ និងការរំលោភដែលកើតមានក្នុងបរិបទនៃការរៀបការដោយបង្ខំតែប៉ុណ្ណោះ ។[១៧]

ការិយាល័យសហព្រះរាជអាជ្ញា ក៏មិនបានស្នើសុំឲ្យមានការស៊ើបអង្កេតបឋមលើអំពើហិង្សាផ្លូវភេទ និងអំពើហិង្សាយេនឌ័រនៅក្នុងសំណុំរឿង០០៣ និង០០៤ដែរ ។ បន្ទាប់មក នៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤ ភាគីអន្តរជាតិនៃការិយាល័យសហព្រះរាជអាជ្ញាបានដាក់សេចក្តីស្នើសុំបន្ថែមពាក់ព័ន្ធនឹងសំណុំរឿង០០៤ ដោយស្នើសុំឲ្យមានការស៊ើបអង្កេតនៅក្នុងស្រុកសំខាន់ៗដែលមានអំពើហិង្សាផ្លូវភេទ និងការរំលោភកើតឡើង ទាំងនៅក្នុង និងក្រៅបរិបទនៃការរៀបការដោយបង្ខំ ដូចជា "ករណីមួយចំនួនដែលស្ត្រីត្រូវបានរំលោភមុនពេលយកទៅសម្លាប់ និងករណីមួយចំនួនទៀត ស្ត្រីរូបណាដែលបានរាយការណ៍អំពីការរំលោភនៅក្នុងរបបខ្មែរក្រហម ស្ត្រីទាំងនោះត្រូវបានយកទៅសម្លាប់នៅពេលក្រោយមក" ។[១៨]

ខណៈដែលការវិវត្តន៍នេះបានផ្តល់ឲ្យនូវពន្លឺនៃក្តីសង្ឃឹម ដែលថាអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានៅទីបំផុតនឹងដោះស្រាយករណីអំពើហិង្សាផ្លូវភេទនៅក្រៅបរិបទនៃការរៀបការដោយបង្ខំ ប៉ុន្តែក៏នៅតែមានភាពមន្ទិលសង្ស័យនៅឡើយ ថាតើសំណុំរឿង០០៤អាចនឹងត្រូវយកមកជំនុំជម្រះសេចក្តីដែរឬយ៉ាងណា ។ ការស៊ើបអង្កេតក្នុងសំណុំរឿង០០៣ និង០០៤ បានជាប់គាំងចាប់តាំងពីឆ្នាំ២០០៩ និងបានទទួលរងការចោទប្រកាន់ថាមានការជ្រៀតជ្រែកផ្នែកនយោបាយ និងការប្រព្រឹត្តខុសក្រមសីលធម៌ និងវិជ្ជាជីវៈក្នុងការស៊ើបអង្កេត ដោយរាប់បញ្ចូលទាំងការថ្លែងផ្ទួនៗជាសាធារណៈដោយមន្ត្រីរាជរដ្ឋាភិបាល ដូចជា នាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលថាសំណុំរឿង០០៣ និង០០៤ "មិនត្រូវបន្ត" និងមិនត្រូវបញ្ជូនទៅតុលាការដើម្បីធ្វើការជំនុំជម្រះ ។[១៩]

---

[១៧] ដដែល ដូចខាងលើ ។

[១៨] សេចក្តីប្រកាសព័ត៌មាន, សហព្រះរាជអាជ្ញាអន្តរជាតិស្នើឲ្យមានការស៊ើបអង្កេតទាក់ទងនឹងអំពើហិង្សាផ្លូវភេទ និងអំពើហិង្សាដោយផ្អែកលើយេនឌ័រ ក្នុងសំណុំរឿង០០៤ (ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤) ។ សូមមើលគេហទំព័រ www.eccc.gov.kh/en/articles/internationalco-prosecutor-requests-investigation-alleged-sexual-and-gender-based-violence

[១៩] យ៉ាងហោចណាស់របាយការណ៍មួយត្រូវបានបញ្ជូនទៅឲ្យអគ្គលេខាធិការអង្គការសហប្រជាជាតិលោក បាន គីមូន ដោយផ្ទាល់ ។ សូមមើលគម្រោងផ្តួចផ្តើមឲ្យមានយុត្តិធម៌សង្គមសេរី "ការវិវត្តន៍ថ្មីនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១១) ។ នៅលើគេហទំព័រ www.opensocietyfoundations.org/sites/default/files/eccc-developments-20111114.pdf. សូមមើលផងដែរ អង្គការឃ្លាំមើលសិទ្ធិមនុស្ស, កម្ពុជា ៖ ចៅក្រមស៊ើបអង្កេតបទឧក្រិដ្ឋខ្មែរក្រហមគួរតែលាឈប់ ៖ ការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកកិច្ចការច្បាប់ខកខានក្នុងការធ្វើសកម្មភាពបើទោះបីជាមានការប្រព្រឹត្តិកំហុសវិជ្ជាជីវៈ (ថ្ងៃទី៣ ខែតុលា ឆ្នាំ២០១១) www.hrw.org/news/2011/10/03/cambodia-judges-investigating-khmer-rouge-crimes-should-resign ។

ហេតុដូច្នេះហើយ ការរំពឹងទុកជាច្រើនផ្តោតតែទៅលើសំណុំរឿង០០២ ។ ដើម្បីពន្លឿនកិច្ចដំណើរការនីតិវិធីសវនាការ អង្គជំនុំជម្រះសាលាដំបូងបានបំបែកបទចោទក្នុងសំណុំរឿង០០២ ទៅជាការជំនុំជម្រះរឿងក្តី «ផ្នែកតូចៗ» ដើម្បីសម្រេចឲ្យបានយ៉ាងហោចណាស់សាលក្រមចុងក្រោយមួយក្នុងចំណោមបទចោទដទៃទៀត មុនពេលដែលជនជាប់ចោទស្លាប់បាត់បង់ជីវិត ។ សំណុំរឿង០០២ ដំណាក់កាលទី១ ដែលបានបិទបញ្ចប់ការសួរដេញដោលកាលពីខែតុលា ឆ្នាំ២០១៣ បានផ្តោតជាសំខាន់លើការជម្លៀសប្រជាជនដោយបង្ខំពីទីប្រជុំជនទៅកាន់ទីជនបទ ។ ទោះបីជាយ៉ាងណាក៏ដោយ កាលពីពេលថ្មីៗនេះអង្គជំនុំជម្រះសាលាដំបូងបានប្រកាសថា សំណុំរឿង០០២ ដំណាក់កាលទី២ អាចនឹងបញ្ចូលការរៀបការដោយបង្ខំដោយផ្អែកលើមូលដ្ឋានច្បាប់ជាតិ[២០] ជាជាងការកំណត់អំពីតំបន់ជាក់លាក់ណាមួយនៅក្នុងប្រទេស ដូចដែលបានជជែកវែកញែកដោយសហព្រះរាជអាជ្ញានាពេលកន្លងទៅ ។

បើទោះបីជាស្ថិតនៅក្នុងតម្លៃណាក៏ដោយ អត្ថប្រយោជន៍ទាំងនេះ គឺជាឱកាសល្អបំផុតសម្រាប់តុលាការ ដើម្បីចូលរួមចំណែកលើកស្ទួយដល់វិស័យច្បាប់ដែលមិនធ្លាប់មានពីពេលមុន ក្នុងគោលបំណងឆ្លើយតបទៅនឹងឧក្រិដ្ឋកម្មផ្លូវភេទ និងឧក្រិដ្ឋកម្មដោយផ្អែកលើយេនឌ័រ នៅក្នុងអំឡុងពេលមានជម្លោះ និងអំពើសាហាវឃោរឃៅនៅក្នុងសកលលោក ។ សរុបសេចក្តីមក ការរួមបញ្ចូលអង្គហេតុទាក់ទងនឹងការរៀបការដោយបង្ខំនៅក្នុងសំណុំរឿង០០២ ដំណាក់កាលទី២ នឹងអនុញ្ញាតឲ្យអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាអាចពន្យល់ដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលមានភាពក្លាហានក្នុងការទម្លាយនូវភាពស្ងៀមស្ងាត់ដែលលាក់ទុកអស់រយៈកាលជាច្រើនទសវត្សរ៍ បើទោះបីជាត្រូវប្រឈមនឹងការរើសអើង និងការពេបជ្រាយពីសង្គម អំពីមូលហេតុចម្បងនៃអំពើហិង្សាទាក់ទងនឹងបញ្ហាយេនឌ័រដែលកើតចេញពីអំពើហិង្សាដែលត្រូវបានប្រព្រឹត្តិនៅទូទាំងប្រទេសនៅក្រោមរបបខ្មែរក្រហម ។

---

[២០] សូមមើលសេចក្តីសម្រេចស្តីអំពីការបំបែកសំណុំរឿងបន្ថែមលើសំណុំរឿង០០២ ដំណាក់កាល២ និងវិសាលភាពនៃសំណុំរឿងលេខ០០២ ដំណាក់កាលទី២, សំណុំរឿង០០២ ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០០៧ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, អង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌទី១៣៣ (ថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៤) ។